**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Sep-2012, 13:48
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (១៦)

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ :

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្ដឹងសាទុក្ខឆ្លាមៗជំទាស់នៅនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១**

**សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា**

---

**<u>ដាក់ដោយ:</u>**

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង

Andrew CAYLEY

**<u>ផ្ញើជូន:</u>**

**<u>ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល:</u>**

ចៅក្រម គង់ ស្រីម ជាប្រធាន

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម មុំង មុន្នីចរិយា

**<u>ចម្លងជូន:</u>**

**<u>មេធាវីជនជាប់ចោទ</u>**

**<u>អៀង ធីរិទ្ធ:</u>**

ផាត់ ពៅសៀង

Diana ELLIS, QC

ចៅក្រម C. N. JAYASIINGHE

ចៅក្រម យ៉ា ណារិន

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម F.N.M. MUMBA

**សហព្រះរាជអាជ្ញាអន្តរជាតិ**

**រដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាដាក់សារណាបន្ថែមទាំងនេះ ("សារណា") ទៅតាមការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") នៅក្នុង *សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែមលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចដោះលែង អៀង ធីរិទ្ធ*[1]។ បំណងរបស់សហព្រះរាជអាជ្ញា គឺមួយគត់ ដើម្បីលើកឡើងភស្តុតាង និងទឡ្ហីករណ៍គាំទ្រនានាដែលមិនអាចលើកឡើងឱ្យបានពេញលេញ នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន។ សារណានេះគួរតែយកទៅអានរួមជាមួយបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[2]។

2. បន្ទាប់ពីបានដាក់បណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាបានទទួលសេចក្ដីសម្រេចមួយរបស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ដែលជ្រើសតាំងកូនស្រីជនជាប់ចោទឈ្មោះ វេជ្ជបណ្ឌិត អៀង វិជីដា ជាអ្នកអាណាព្យាបាលទូទៅសម្រាប់ជនជាប់ចោទ អនុលោមទៅតាមមាត្រា ២៤ *ff* និង ១១០៤ *ff* នៃក្រមរដ្ឋប្បវេណីកម្ពុជា[3]។ តាមរយៈសេចក្ដីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សហព្រះរាជអាជ្ញាយល់ថា វេជ្ជបណ្ឌិត អៀង វិជីដា បានដាក់សំណើមួយសុំចាប់ផ្ដើមថែទាំជនជាប់ចោទ តាមរយៈអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ បន្ទាប់ពីមានការវាយតម្លៃឡើងវិញទៅលើស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទ ដោយអ្នកជំនាញបីរូប ដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅជួយដោះស្រាយទៅតាមលទ្ធភាព ចំពោះបញ្ហាដែលមេធាវីការពារក្ដីពុំមានលទ្ធភាពទទួលការណែនាំពីជនជាប់ចោទបាន[4]។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាយល់

---

[1] ឯកសារ **E138/1/10/1/3/1** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែមលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចដោះលែង អៀង ធីរិទ្ធ, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២។

[2] ឯកសារ **E138/1/10/1/1** បណ្ដឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីកាយសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("បណ្ដឹងសាទុក្ខ")។

[3] ឯកសារ **E138/1/10/1/2/3.1** សំណុំរឿងរដ្ឋប្បវេណីលេខ ១៦៣៨ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២, សេចក្ដីសម្រេចលេខ ២៨៨, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។

[4] ឯកសារ **E1/12.1** ប្រតិចារឹក, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ត្រង់ទំព័រ ១០១ (ភាសាអង់គ្លេស); ឯកសារ **E131/1/5** បញ្ជីឈ្មោះឯកសារដែលត្រូវស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងឈ្មោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចនឹងត្រូវបានកោះហៅក្នុងអំឡុងពេលសវនាការរយៈពេលបីសប្ដាហ៍ដំបូង, ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ

ឃើញថា សារណាទាំងនេះ និងសារណាតាមផ្លូវច្បាប់ និងសេចក្ដីសម្រេចនានាដែលអាចនឹងដាក់ និងចេញនាពេលខាងមុខពាក់ព័ន្ធនឹងជនជាប់ចោទនោះ គួរតែចម្លងជូន វេជ្ជបណ្ឌិត អៀង ធីរិទ្ធ ផងដែរ។

3. នៅក្នុងសារណានេះ សហព្រះរាជអាជ្ញាលើកឡើងនូវបញ្ហាមូលដ្ឋានស្ដីពីបណ្ដឹងសាទុក្ខ ពោលគឺការដាក់វិធានការនានានៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ទៅលើជនជាប់ចោទ។

## II. សារណាបន្ថែមស្ដីពីវិធានការនានានៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

### ក. វិធានការនានានៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ស្របទៅតាមគោលបំណងស្របច្បាប់របស់សាធារណជន ឬសពីការធានានូវវត្តមានរបស់ជនជាប់ចោទក្នុងសវនាការ

4. ត្រង់កថាខណ្ឌ ៧ នៃបណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយខកខានមិនបានពិចារណា ឬអនុវត្តមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CCP”) ជា “មូលដ្ឋានគតិយុត្តច្បាស់លាស់ ដើម្បីដាក់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមទម្រង់ផ្សេងៗ” លើជនជាប់ចោទ អៀង ធីរិទ្ធ “នៅពេលដោះលែងទេ”[5]។ ត្រង់កថាខណ្ឌ ៨ នៃបណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលបដិសេធមិនអនុវត្តតាមវិធាន ៦៥ និង ៨២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលផ្ដល់ជាមូលដ្ឋានគតិយុត្តសម្រាប់ដាក់លក្ខខណ្ឌដោយបង្ខំទៅលើជនជាប់ចោទ ដែលមិនកំពុងស្ថិតក្នុងលទ្ធភាពសមហេតុផលដែលអាចនឹងយក

---

២០១១ ត្រង់កថាខណ្ឌ ៣៖ “បច្ចុប្បន្ន សហមេធាវីការពារក្ដីពុំអាចទទួលការណែនាំពីជនជាប់ចោទបានឡើយ”; ឯកសារ **E131/3** ការជូនដំណឹងរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ទាក់ទងនឹងសេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់ និងការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់របស់ជនជាប់ចោទនៅសវនាការ, ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់កថាខណ្ឌ ៣៖ “ដូចដែលបានចង្អុលបង្ហាញកាលពីលើកមុន [...] មេធាវីការពារក្ដីមិនអាចទទួលបាននូវការណែនាំពីជនជាប់ចោទបានឡើយ ដោយស្ថានភាពស្មារតីរបស់គាត់ និងជាពិសេសការចុះអន់ថយនៃការចងចាំរបស់គាត់”។

[5] ឯកសារ **E138/1/10** សេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”) ត្រង់កថាខណ្ឌ ៣៣។

មកជំនុំជម្រះក្តីបាន។ ជាងនេះទៀត សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនត្រឹមតែមិនបានយកចិត្តទុកដាក់ទៅលើចំណុចនៃច្បាប់ជាធរមានដោយផ្ទាល់ ដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះទេ[6] តែក៏បានភាន់ច្រឡំជាមូលដ្ឋាននូវគោលបំណង និងយុត្តិកម្មសម្រាប់ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ វិធានការតឹងរ៉ឹងដទៃទៀតស្តីពីការដោះលែងដែរ។ នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ សំអាងហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងបង្ហាញថា កម្មវត្ថុតែមួយគត់នៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ការដោះលែងជនជាប់ចោទដោយមានលក្ខខណ្ឌ ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីគឺ ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលការជំនុំជម្រះក្តីបន្តឡើងវិញ[7] ហេតុនេះ ការដាក់កំហិត ឬ វិធានការដោយបង្ខំទាំងនេះ ដែល "មិនមាន

---

[6] ឯកសារ **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទី១") ត្រង់កថាខណ្ឌ ៤៥៖ "នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ មតិភាគតិចបានលើកឡើងថា មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "អនុញ្ញាតឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាជម្រើសក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះ" និងមិនយកមកអនុវត្តចំពោះជនជាប់ចោទដែលពុំមានសម្បទា នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក "ដោយពុំមានក្តីសង្ឃឹមថាសមហេតុផលណាមួយក្នុងការបន្តឡើងវិញ"។ [...] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មតិភាគច្រើននៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់មិនមានន័យថា ការត្រួតពិនិត្យតាមផ្លូវតុលាការមិនមានចំពោះអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែមិនមាននៅក្នុងកាលៈទេសៈពិសេសទាំងនេះប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលទទួលយកនូវមតិភាគច្រើននៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ដែលថា ការត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាននៅសាលាដំបូងនៅកម្ពុជា និងមាននៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក។ ដោយសារសាលាដំបូងត្រូវបានអនុញ្ញាតឲ្យអនុវត្តការឃុំខ្លួន ដូច្នេះជាការសមហេតុផល ដែលតុលាការនេះត្រូវបានអនុញ្ញាតឲ្យអនុវត្តនូវវិធានការដែលពុំសូវរឹតត្បិត។ ការបកស្រាយបែបនេះមានលក្ខណៈសមស្របទៅនឹងវិធាន ៨២(២) នៃវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ "ឲ្យដោះលែងដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ទោះបីជាពុំមានបទប្បញ្ញត្តិចែងអំពីលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងមាត្រា ៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏ដោយ។ គួរកត់សម្គាល់ផងដែរថា ពាក្យពេចន៍ "ដីសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ដែលត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុង និងត្រូវបានប្រើប្រាស់ក្នុងវិធាន ៦៥ នៃវិធានផ្ទៃក្នុងនោះ រួមបញ្ចូលនូវវិធានការផ្សេងៗ ដែលអាចដាក់លើជនជាប់ចោទជំនួសឲ្យការឃុំខ្លួន រួមទាំងការបង្គាប់នានាតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា" [លុបឯកសារយោងខាងក្នុង]។ *សូមមើលផងដែរ* កថាខណ្ឌ ៤៦។

[7] ឯកសារ **E138/1/10** សេចក្តីសម្រេចដែលត្រូវបានជំទាស់, ជើងទំព័រ ៥ *ខាងលើ* ត្រង់កថាខណ្ឌ ២៨, ៣៣-៣៦។

លទ្ធភាពសមហេតុផលដែលជនជាប់ចោទនឹងត្រូវយកមកជំនុំជម្រះ ក្នុងពេលអនាគតដែលគេអាចប្រមើលដឹង" ពុំមានជាមូលដ្ឋានគតិយុត្តទាល់តែសោះ[8]។

5. ខណៈដែលការធានាអំពីវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការ នៅតែជាគោលបំណងចម្បងនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ សហព្រះរាជអាជ្ញាលើកឡើងថា នេះជាគោលបំណងស្របច្បាប់តែមួយគត់ដែលត្រូវយកមកអនុវត្ត។ ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណា ទៅលើគោលបំណងនៃវិធានការនានានៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលច្បាប់កម្ពុជា និងច្បាប់នៅ អ.វ.ត.ក បានអនុញ្ញាតទេ។ ឧទាហរណ៍ មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងពីកាតព្វកិច្ចមួយចំនួនសម្រាប់អនុវត្ត នៅពេលដែលជនជាប់ចោទត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ លក្ខខណ្ឌជាច្រើនក្នុងចំណោមលក្ខខណ្ឌទាំងនេះមិនអាចត្រូវបានចាត់ទុកថា មានទំនាក់ទំនងទៅនឹងការធានាអំពីវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការទេ តែផ្ទុយទៅវិញវាពាក់ព័ន្ធជាមួយនឹងការធានានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីតុលាការ ការបង្ការបទល្មើស ការការពារជនរងគ្រោះ និងអ្នកដែលអាចក្លាយជាសាក្សី និងការថែរក្សាសណ្តាប់ធ្នាប់សាធារណៈតែប៉ុណ្ណោះ។ លក្ខខណ្ឌទាំងនេះរួមមាន កាតព្វកិច្ច "មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ"[9] "មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ"[10] "មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ [...]"[11] និង "មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ"[12]។

6. ជាងនេះទៀត មូលដ្ឋាននានាដែលបទប្បញ្ញត្តិពាក់ព័ន្ធនៅ អ.វ.ត.ក ដែលអនុវត្តឲ្យមានការកំហិតទៅលើសេរីភាពរបស់ជនជាប់ចោទមិនត្រូវបានកំណត់ ចំពោះការធានាវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការទេ។ វិធាន ៦៥(១) ចែងថា ការដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះសាលាដំបូង តាម

---

[8] ឯកសារ **E138/1/10** *ដូចខាងលើ*, ត្រង់កថាខណ្ឌ ៣៣។

[9] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ២២៣(៣)។

[10] *ដូចខាងលើ*, មាត្រា ២២៣(៨)។

[11] *ដូចខាងលើ*, មាត្រា ២២៣(១០)។

[12] *ដូចខាងលើ*, មាត្រា ២២៣(១២)។

វិធាន ៨២(២) “ត្រូវ [...] ដាក់លក្ខខណ្ឌទាំងនេះជាការចាំបាច់ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និង *ដើម្បីការពារអ្នកដទៃទៀត*”[13]។ វិធាន ៦៣ ដែលគ្រប់គ្រងការដោះលែងបណ្តោះអាសន្នក៏អាចយកមកអនុវត្តចំពោះចំណុចនេះបានដែរ ដោយសារថា នៅក្នុងសេចក្តីសម្រេចដែលត្រូវបានជំទាស់ អង្គជំនុំជម្រះសាលាដំបូងទំនងជាចាត់ទុកគោលការណ៍ និងយុត្តិកម្មតាមផ្លូវច្បាប់ដែលនៅខាងក្រោយការដោះលែងដោយមានលក្ខខណ្ឌ ដូចជាគោលការណ៍ និងយុត្តិកម្មដែលនៅខាងក្រោយការឃុំខ្លួនដែរ[14]។ វិធាន ៦៣(៣)(ខ) អនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ជាការចាំបាច់ *ដែលក្នុងចំណោមនោះ* គឺដើម្បី “រារាំងកុំឲ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតអំពើឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក”[15] “ការពារសន្តិសុខឲ្យជនត្រូវចោទ ឬ រក្សាសណ្តាប់ធ្នាប់សាធារណៈ”[16]។

7. ជាចុងក្រោយ ការណែនាំបកស្រាយក្នុងវិធាន ២១ គាំទ្រទស្សនៈដែលថាសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌អាចទទួលបានការគោរពពេញលេញ តែនៅពេលដែលសិទ្ធិនេះត្រូវបានពិចារណាដោយយោងតាមកាលៈទេសៈទាំងអស់នៃសំណុំរឿង ដោយមិនត្រឹមតែរួមបញ្ចូលទាំងសិទ្ធិ និងផលប្រយោជន៍របស់ជនជាប់ចោទឡើយ ប៉ុន្តែរួមបញ្ចូលផងដែរនូវសិទ្ធិរបស់ជនរងគ្រោះ និងភាគីផ្សេងៗនៃកិច្ចដំណើរការនីតិវិធីផងដែរ[17] លក្ខណៈ និងទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបាន

---

[13] វិធាន ៦៥(១) [គូសបញ្ជាក់បន្ថែម]។

[14] បន្ទាប់ពីបានសន្និដ្ឋានថា ពុំមានមូលដ្ឋានគតិយុត្តិសម្រាប់បន្តឃុំខ្លួនជនជាប់ចោទនោះ ដោយផ្អែកលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ពុំមានលទ្ធភាពសមហេតុផលដែលថា ជនជាប់ត្រូវអាចនឹងមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះក្តីនាពេលអនាគតដែលអាចប្រមើលដឹងនោះ អង្គជំនុំជម្រះសាលាដំបូងស្រាប់តែសន្និដ្ឋានភ្លាមថា ហេតុនេះពុំមានមូលដ្ឋានគតិយុត្តិសម្រាប់កំណត់លក្ខខណ្ឌដោយបង្ខំផ្សេងទៀត ឬ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមទម្រង់ផ្សេងទៀត បន្ទាប់ពីការដោះលែងនោះទេ, សូមមើលឯកសារ **E138/1/10** សេចក្តីសម្រេចដែលត្រូវបានជំទស់, ជើងទំព័រ ៥ *ខាងលើ*, ត្រង់កថាខណ្ឌ ២៩-៣០, ៣៣។

[15] វិធាន ៦៣(៣)(ខ)(១)។ ទំនាក់ទំនងរវាងបញ្ញត្តិនេះនឹងវិធាន ៣៥ គួរឲ្យកត់សម្គាល់ដែរ ជាពិសេសនៅពេលពិចារណាពីការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូងនៃការអនុវត្តបាននូវវិធាន ៣៥ ចំពោះជនជាប់ចោទ អៀង ធីរិទ្ធ៖ ឯកសារ **E138/1/10** សេចក្តីសម្រេចដែលត្រូវបានជំទាស់, ជើងទំព័រ ៥ *ខាងលើ* ត្រង់កថាខណ្ឌ ៣៨។

[16] វិធាន ៦៣(៣)(ខ)(៤-៥)។

[17] វិធាន ២១(១)(ក)។

ចោទប្រកាន់ និងភាពចាំបាច់ដើម្បីស្វែងរកយុត្តិធម៌[18] ផលប្រយោជន៍សាធារណៈក្នុងការចោទប្រកាន់ (ដែលរួមបញ្ចូលនូវគោលដៅនៃការបញ្ចប់និទណ្ឌភាព ការបង្កើនទំនុកចិត្តរបស់សាធារណជននៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ និងការលើកកម្ពស់ការផ្សះផ្សាជាតិ) និងការពិចារណាអំពីសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ក្នុងចំណោមកត្តាផ្សេងៗ។

8. ដូចដែលបានបញ្ជាក់ក្នុងបណ្តឹងឧទ្ធរណ៍ តាមសំអាងហេតុទាំងនេះ សហព្រះរាជអាជ្ញាអះអាងយ៉ាងសាមញ្ញថា "កំហុសអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងខកខានពុំបានអនុវត្តបានត្រឹមត្រូវនូវយុត្តាធិការរបស់ខ្លួន តាមរយៈការពិចារណាអំពីវិសាលភាពពេញលេញនៃវិធានការជាជម្រើសផ្សេងៗ និងការរក្សាតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទ និងទំនាស់ផលប្រយោជន៍ រួមទាំងភាពចាំបាច់ដើម្បីធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី"[19]។

### ខ. លក្ខខណ្ឌគតិយុត្តដ៏រឹងមាំសម្រាប់ការកំហិតសិទ្ធិមនុស្សជាសារវន្តអាចយកមកអនុវត្តបាននៅក្នុងកាលៈទេសៈទាំងនេះ

9. នៅត្រង់កថាខណ្ឌ ១៤ នៃបណ្តឹងសាទុក្ខនេះ សហព្រះរាជអាជ្ញាអះអាងថាៈ

> *ការដាក់លក្ខខណ្ឌតឹងរ៉ឹងទៅលើសម្បទាជនជាប់ចោទក្នុងការចូលរួមសវនាការ និងផ្សេងពីនេះទៅលើសិទ្ធិសេរីភាព នៅពេលមានភាពស៊ីសង្វាក់ទាំងស្រុងជាមួយយុត្តិសាស្ត្រ និងទម្លាប់អនុវត្តន៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាក៏ដោយ ក៏ការដាក់លក្ខខណ្ឌរឹតត្បិតលើជនជាប់ចោទដែលពុំមានសម្បទាដើម្បីចូលរួមសវនាការ និងជនជាប់ចោទចោទដែលត្រូវដោះលែង ត្រូវតែបំពេញលក្ខណវិនិច្ឆ័យនៃសមាមាត្រជាទូទៅសម្រាប់ការកំហិតសិទ្ធិ ដែលមានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវតែជឿជាក់ថាលក្ខខណ្ឌបែបនេះមាន* ភាពសមស្របចាំបាច់ *និង* សមាមាត្រ *ក្នុងកាលៈទេសៈទាំងអស់នេះ។*

[18] វិធាន ២១(២)។ ឯកសារ **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទីមួយ, *ដូចជើងទំព័រលេខ* ៦ ខាងលើ ត្រង់កថាខណ្ឌ ២៨។

[19] ឯកសារ **E138/1/10/1/1** បណ្តឹងសាទុក្ខ, *ដូចជើងទំព័រលេខ* ២ ខាងលើ ត្រង់កថាខណ្ឌ ៨។

សហព្រះរាជអាជ្ញាសូមយោងទៅដល់លក្ខខណ្ឌសមាមាត្រ នៃវិធានការរឹតត្បិតលើការដោះលែងបណ្ដោះអាសន្ន ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបញ្ជាក់នៅក្នុងសំណុំរឿង *Talić* និង *Jokić*[20]។

10. សហព្រះរាជអាជ្ញាសូមអះអាងទៀតថាលក្ខណវិនិច្ឆ័យនៃគោលការណ៍សមាមាត្រ ត្រូវបានយកមកអនុវត្តយ៉ាងខ្ជាប់ខ្ជួន ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ និងប្រព័ន្ធគតិយុត្តិជាតិមួយចំនួន ទាក់ទិននឹងវិធានការនានាដែលរឹតត្បិតលើបណ្ដុំនៃសិទ្ធិជាសារវន្ត ដែលពុំមែនជាការរឹតត្បិតសិទ្ធិទទួលបានសេរីភាពតែមួយមុខឡើយ។ ដូចដែលតុលាការកំពូលកាណាដាបានកត់សម្គាល់៖ "ថ្វីបើលក្ខខណវិនិច្ឆ័យនៃគោលការសមាមាត្រមានប្រភេទខុសៗគ្នាទៅតាមកាលៈទេសៈក៏ដោយ ក៏នៅក្នុងសំណុំរឿងនីមួយៗ តុលាការចាំបាច់ត្រូវរក្សាតុល្យភាពនៃផលប្រយោជន៍សង្គម ជាមួយផលប្រយោជន៍របស់បុគ្គល និងក្រុម"[21]។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នានានៃតុលាការ *ពុំអចិន្ត្រៃយ៍* ផ្ដល់ជាគំរូសន្និកសន្ធាប់អំពីការអនុវត្តលក្ខខណ្ឌសមាមាត្រ ទៅលើកាលៈទេសៈនានាពាក់ព័ន្ធនឹងសិទ្ធិជាសារវន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាក់ស្ដែង នៅក្នុងសំណុំរឿង *Stanišić និង Simatović,* អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសម្រេចថា៖

> *ជនជាប់ចោទដែលបង្ហាញខ្លួននៅចំពោះមុខតុលាការអន្តរជាតិ មានសិទ្ធិទទួលបានការធានាជាអប្បបរមាជាក់លាក់មួយចំនួន [...] [រួមទាំង] សិទ្ធិ "ទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់ជនជាប់ចោទ" [...] យ៉ាងណាមិញ សិទ្ធិនេះពុំមែនជាសិទ្ធិដាច់ខាតឡើយ។ ជនជាប់ចោទអាចលះបង់ ឬបាត់បង់សិទ្ធិមានវត្តមាននៅសវនាការ។ ជាឧទាហរណ៍ អនុលោមតាមវិធាន ៨០ (ខ) នៃវិធានផ្ទៃក្នុង [...] អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចេញពីបន្ទប់សវនាការ និងបន្តកិច្ចដំណើរការនីតិវិធី ដោយពុំចាំបាច់មានវត្តមានរបស់*

[20] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Talić,* លេខសំណុំរឿង IT-99-36-T, សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Momir Talić ជាបណ្ដោះអាសន្ន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២, ត្រង់កថាខណ្ឌ ២៣; យោងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Jokić*, លេខសំណុំរឿង IT-02-53-PT, សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Jokić ជាបណ្ដោះអាសន្ន , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២, ត្រង់កថាខណ្ឌ ១៨។

[21] សំណុំរឿង *R.* ទល់នឹង *Oakes* [1986] 1 S.C.R. 103 ត្រង់កថាខណ្ឌ ៧០ (អង្គជំនុំជម្រះតុលាការកំពូលកាណាដា)។

*ជនជាប់ចោទ ប្រសិនបើជនជាប់ចោទបន្តប្រព្រឹត្តទង្វើរំខានដល់សវនាការ បន្ទាប់ពីមានការព្រមានថាទង្វើបែបនេះ អាចអនុញ្ញាតឲ្យមានការនាំខ្លួនជនជាប់ចោទចេញពីបន្ទប់សវនាការ។ [...] អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ទាំងនោះបានសម្រេចទៀតថាវិធាននេះ ពុំកំហិតត្រឹមជាការរំខានដោយចេតនាឡើយ។ យ៉ាងណាមិញ ក្នុងការវាយតម្លៃអំពីការរឹតត្បិតដាក់លើការធានាសិទ្ធិដូចមានចែងក្នុងលក្ខន្តិកៈ ដូចជាសិទ្ធិមានវត្តមានក្នុងសវនាការ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ទាំងនោះពិចារណាអំពីគោលការណ៍សមាមាត្រ ដែលអនុលោមតាមគោលការណ៍នេះ ការរឹតត្បិតណាមួយលើសិទ្ធិជាសារវន្តត្រូវតែបម្រើឲ្យគោលបំណងសំខាន់គ្រប់គ្រាន់ និងមិនត្រូវប៉ះពាល់សិទ្ធិលើសពីការចាំបាច់ដើម្បីសម្រេចគោលបំណងនេះឡើយ*[22] ។

11. ក្នុងសំណុំរឿង *Milošević*, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY ក្នុងការសម្រេចថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ជាសារវន្ត តាមរយៈការពុំបានទទួលស្គាល់ថាការរឹតត្បិតណាមួយទៅលើសិទ្ធិតំណាងខ្លួនឯង "ត្រូវតែរឹតត្បិតក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីការពារផលប្រយោជន៍របស់តុលាការ ក្នុងការធានាបានការជំនុំជម្រះឆាប់រហ័សសមស្រប"[23] បានលើកឡើងថា៖

*នៅពេលពិនិត្យឡើងវិញអំពីការរឹតត្បិតសិទ្ធិជាសារវន្ត ដូចជាករណីនេះជាដើម យុត្តាធិការជាច្រើន បានទទួលការណែនាំពីគោលការណ៍សមាមាត្រជាមូលដ្ឋានផ្សេងៗគ្នាមួយចំនួន។ ការរឹតត្បិតសិទ្ធិជាមូលដ្ឋានណាមួយត្រូវតែបម្រើឲ្យ*

---

[22] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić និង Franko Simatović*, លេខសំណុំរឿង IT-03-69-AR73.2, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីជំទាស់នឹងសេចក្តីសម្រេចស្តីពីកិច្ចដំណើរការនីតិវិធីនៅថ្ងៃខាងមុខ,ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ៦។

[23] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević*, លេខសំណុំរឿង IT-02-54-AR73.7, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងមេធាវីការពារក្តី (អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ១៧។

*"គោលបំណងសំខាន់គ្រប់គ្រាន់" និងមិនត្រូវ "ប៉ះពាល់សិទ្ធិ...លើសពីការចាំបាច់ដើម្បីសម្រេចគោលបំណងនេះឡើយ"*[24]។

12. អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR ក៏បានបញ្ជាក់អំពីសារៈសំខាន់នៃគោលការណ៍សមាមាត្រនេះនៅក្នុងគ្រប់បរិបទទាំងអស់ដែលពាក់ព័ន្ធនឹងសិទ្ធិ។ ក្នុងសំណុំរឿង *Zigiranyirazo* អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា សិទ្ធិមានវត្តមានរបស់ជនជាប់ចោទ ពុំមែនជាសិទ្ធិដាច់ខាតឡើយ ដោយហេតុថា សិទ្ធិនេះអាចត្រូវបានជនជាប់ចោទលះបង់ ឬបាត់បង់ នៅក្នុងកាលៈទេសៈមួយចំនួនរួមទាំងក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចនាំខ្លួនជនជាប់ចោទ ដែលបន្តរំខានសវនាការចេញពីបន្ទប់សវនាការ ឬដើម្បីបញ្ចៀសការរំខានខ្លាំងក្លាផ្សេងៗនៅសវនាការ។

*ក្នុងការវាយតម្លៃអំពីការរឹតត្បិតជាក់លាក់ណាមួយ ទៅលើការធានាដូចមានចែងក្នុងលក្ខន្តិកៈ ដូចជាសិទ្ធិមានវត្តមានក្នុងសវនាការ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ទាំងនោះពិចារណាអំពីគោលការណ៍សមាមាត្រនេះ ដែលអនុលោមតាមគោលការណ៍នេះ ការរឹតត្បិតណាមួយទៅលើសិទ្ធិជាសារវន្តត្រូវតែបម្រើឱ្យគោលបំណងសំខាន់គ្រប់គ្រាន់ និងមិនត្រូវប៉ះពាល់សិទ្ធិលើសពីការចាំបាច់ដើម្បីសម្រេចគោលបំណងនេះឡើយ។ អញ្ញត្រកម្មជាក់លាក់ដូចមានចែងក្នុងវិធាន ៨0(ខ) និងការលើកឡើងរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY អំពី "ការរំខានខ្លាំងក្លានៅសវនាការ" ផ្តល់វិធានការមួយដែលជួយជាប្រយោជន៍ដល់ការវាយតម្លៃអំពីការរឹតត្បិតផ្សេងៗទៅលើសិទ្ធិមានវត្តមាននៅសវនាការ*[25]។

---

[24] ដូចឯកសារយោងខាងលើ។

[25] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* *Protais Zigiranyirazo*, លេខសំណុំរឿង ICTR-2001-73-AR73, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ (អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTR), ថ្ងៃទី ៣0 ខែ តុលា ឆ្នាំ ២00៦ កថាខណ្ឌ ១៤។ *ជាឧទាហរណ៍ សូមមើលផងដែរ* សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* *Théoneste Bagosora* *និង* *Anatole Nsengiyumva*, លេខសំណុំរឿង ICTR-98-41-A, សាលដីកា (អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTR), ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២0១១ កថាខណ្ឌ ៥៩ ដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ពិភាក្សាអំពីភារកិច្ចរបស់អង្គជំនុំជម្រះដើម្បីពិចារណាអំពីដំណោះស្រាយម្យ៉ាងទៀតក្នុងការសម្រេចរឹតត្បិតសិទ្ធិរបស់ជនជាប់ចោទ ដោយបានកត់សម្គាល់ថាខ្លួនត្រូវតែខិតខំឱ្យបានខ្លាំងក្លា ដើម្បីសម្រាលព្យសនកម្មដែលជនជាប់ចោទទទួលរងក្នុងការដាក់កំហិតណាមួយ។

13. លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលចងកាតព្វកិច្ចកម្ពុជា និងអ.វ.ត.ក រួមទាំងបណ្តុំច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងក្នុងតំបន់ ក៏បានអនុម័តលក្ខណវិនិច្ឆ័យនៃគោលការណ៍សមាមាត្រសម្រាប់ដាក់កំហិតសិទ្ធិ និងសេរីភាពមូលដ្ឋានផងដែរ។ ឧទាហរណ៍ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហាមឃាត់ការដាក់កំហិតលើសិទ្ធិមួយចំនួន ដូចជា សេរីភាពដើរហើរ "លើកលែងតែសិទ្ធិទាំងនេះត្រូវបានកំហិតនៅក្នុងច្បាប់ ក្នុងភាពចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយសិទ្ធិដែលត្រូវបានកំហិតទាំងនេះ ស្របគ្នាទៅនឹងសិទ្ធិនានា ដែលត្រូវបានទទួលស្គាល់នៅក្នុង [...] កតិកាសញ្ញា"[26]។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានសង្កេតឃើញថា "វាពុំត្រឹមត្រូវឡើយ [...] ប្រសិនបើការកំហិតសិទ្ធិទាំងនេះ [ដែលបានកំណត់នៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ] បម្រើគោលបំណងដែលអាចទទួលយកបាននេះ ក៏ប៉ុន្តែ វាក៏ត្រូវចាំបាច់សម្រាប់ការការពារពួកគេផងដែរ"[27]។ ដូចគណៈកម្មាធិការបានកត់សម្គាល់ថា៖

> *វិធានការរឹតបណ្តឹង ត្រូវបានធ្វើឡើងដោយគោរពតាមគោលការណ៍សមាមាត្រ។ វិធានការទាំងនេះ ត្រូវតែមានលក្ខណៈសមស្របដើម្បីទទួលបានការការពារ។ យ៉ាងហោចណាស់វិធានការនេះត្រូវតែជាឧបករណ៍ប៉ះពាល់លើសិទ្ធិតិចតួចបំផុត ក្នុងចំណោមវិធានការទាំងឡាយដែលអាចទទួលបានលទ្ធផលដែលចង់បាននេះ។ ហើយវិធានការទាំងនេះត្រូវសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវបានការពារ*[28]។

14. តុលាការសិទ្ធិមនុស្សអឺរ៉ុប (តុលាការ ECtHR) បានសម្រេចផងដែរថា "[វា] ត្រូវមានទំនាក់ទំនងដោយសមហេតុសមផលនៃគោលការណ៍សមាមាត្ររវាងមធ្យោបាយ ដែលបានប្រើប្រាស់ និង

---

[26] មាត្រា ១២(៣) នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ 999 U.N.T.S. 171 (ចូលជាធរមាននៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៧៦)។

[27] អង្គការសហប្រជាជាតិ លិខិតុករណ៍សិទ្ធិមនុស្សអន្តរជាតិ កម្រងយោបល់ និងអនុសាសន៍ទូទៅ អនុម័តដោយសន្ធិសញ្ញា សិទ្ធិមនុស្សអន្តរជាតិ HRI/GEN/1/Rev. 6 ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣ ត្រង់ទំព័រ ១៧៦ កថាខណ្ឌ ១៤។

[28] *ដូចខាងលើ*។

គោលបំណងចង់បានតាមរយៈវិធានការណាមួយនោះ"[29] ហើយត្រូវគោរពតាមលក្ខណវិនិច្ឆ័យនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនទាំងមូល។ យុត្តិសាស្ត្ររបស់តុលាការ ECtHR កំណត់អំពីធាតុចំនួនបីដែលត្រូវយកមកពិចារណា នៅពេលបំពេញលក្ខណវិនិច្ឆ័យនៃគោលការណ៍សមាមាត្រនេះ៖ (១) នីត្យានុកូលភាព (២) ធម្មានុភាព (៣) ភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ[30]។ លក្ខខណ្ឌនីត្យានុកូលភាព ចែងថា ការដាក់កំហិតណាមួយ ត្រូវមានមូលដ្ឋាននៅក្នុងច្បាប់ក្នុងស្រុក ហើយត្រូវស្របតាមអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបផងដែរ។ ចំពោះធម្មានុភាព គឺសំដៅលើយុត្តិកម្មចំពោះការកំហិតសិទ្ធិ ដែលបានស្នើឡើងចំពោះបុគ្គល ឬក្រុមណាមួយ[31]។ តុលាការ ECtHR បានសង្ខេប "ភាពចាំបាច់" ដូចខាងក្រោមនេះ៖

*(ក) "គុណនាមនៃពាក្យ 'ដែលចំបាច់' ពុំមែនជាសទិ្ទសន័យនៃពាក្យ 'ដែលជៀសមិនរួច' ឡើយ។ ហើយវាក៏ពុំមានភាពបត់បែនដូចពាក្យ 'ដែលអាចទទួលយកបាន' 'ដែលសាមញ្ញ' 'ដែលសមហេតុផល' 'ទៅតាមការចង់បាន' ឡើយ។ (ខ) រដ្ឋភាគីនៃអនុសញ្ញា បានទទួលការអនុញ្ញាតមួយចំនួន ក៏ប៉ុន្តែពុំមែនថាពុំមានដែនកំណត់នោះឡើយ នៅក្នុងការកំហិតសិទ្ធិនេះ ហើយតុលាការមានឆន្ទានុសិទ្ធិសម្រេចចុងក្រោយថាតើការកំហិតសិទ្ធិទាំងនេះ ស្របតាមអនុសញ្ញាដែរ ឬអត់។ (គ) ឃ្លា 'ដែលចំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ' មានន័យថា ដើម្បី*

---

[29] *Pressos Compania Naviera S.A. និងជនផ្សេងទៀត ទល់នឹង ប្រទេសបែលហ្ស៊ិក* [1995] តុលាការ ECHR 47i ពាក្យសុំលេខ 17849/91 (តុលាការ ECtHR) ត្រង់កថាខណ្ឌ ៣៨។

[30] Katrougalos, Georges និង Daphne Akoumianaki, "L'application du principe de proportionnalité dans le champs des droits sociaux," អត្ថបទស្ដីពីសន្និបាតពិភពលោកនៃសមាគមអន្តរជាតិនៃច្បាប់រដ្ឋធម្មនុញ្ញ ប្រទេស មិសិក ថ្ងៃទី ៦ - ១០ ខែ ធ្នូ ឆ្នាំ ២០១០ ទំព័រ ១៣។

[31] "ផលប្រយោជន៍ស្របច្បាប់ រួមមាន សន្តិសុខជាតិ បូរណភាពដែនដី និងសុវត្ថិភាពសាធារណៈ សុខមាលភាពសេដ្ឋកិច្ចនៃប្រទេស ការបង្ការការបាត់សណ្ដាប់ធ្នាប់ ឬ ឧក្រិដ្ឋកម្ម ការការពារសុខភាព ឬ សីលធម៌ ការការពារសិទ្ធិ សេរីភាព និងកិត្តិយសនៃជនដទៃ។ ការបង្ការការលាតត្រដាងព័ត៌មាន ដែលបានទទួលដោយសម្ងាត់ និងអព្យាក្រឹត្យភាពនៃតុលាការ"៖ Abiola, Sara, "ខប្បញ្ញត្តិដាក់កំហិតនៅក្នុងរដ្ឋធម្មនុញ្ញជាតិ និងឯកសារសិទ្ធិមនុស្សអន្តរជាតិ៖ វិសាលភាព និងការបកស្រាយតាមផ្លូវតុលាការ" អនុស្សរណៈស្រាវជ្រាវ ដែលត្រូវបានរៀបចំសម្រាប់គំនិតផ្ដួចផ្ដើមនៃសុខភាពសាធារណៈ និងកម្មវិធីច្បាប់សុខភាពសាធារណៈនៃស្ថាប័នសង្គមបើកចំហ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១០ ទំព័រ ១២។

*ឲ្យស្របតាមអនុសញ្ញា ការជ្រៀតជ្រែកនេះ ត្រូវឆ្លើយតបទៅនឹង 'ភាពចាំបាច់ខ្លាំងរបស់សង្គម' និង 'ភាពសមមាត្រទៅនឹងគោលបំណងស្របច្បាប់ដែលខ្លួនចង់បាន'* ”[32] ។

15. ទោះបីជាសហព្រះរាជអាជ្ញា នៅតែបន្តគាំទ្រការដោះលែង អៀង ធីរិទ្ធ ឲ្យមានសេរីភាពពីមន្ទីរឃុំឃាំងក៏ដោយ សហព្រះរាជអាជ្ញាក៏បានស្នើសុំអង្គជំនុំជម្រះឲ្យតម្កល់ការដោះលែងឲ្យមានសេរីភាពនេះ តែស្នើសុំឲ្យគោរពតាមលក្ខខណ្ឌនៃការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ សហព្រះរាជអាជ្ញា ពុំមែនចេះតែធ្វើសំណើសុំនោះទេ។ សហព្រះរាជអាជ្ញានឹងបង្ហាញថា វិធានការនីមួយៗ បានបំពេញតាមលក្ខណវិនិច្ឆ័យតាមផ្លូវច្បាប់ជាធរមាន ដែលអនុញ្ញាតឲ្យដាក់កំហិតសិទ្ធិមានសេរីភាព និងសិទ្ធិសេរីភាពឯកជនរបស់ជនជាប់ចោទ ទៅតាម*ភាពសមរម្យចាំបាច់* និង*សមាមាត្រ* នៅក្នុងកាលៈទេសៈនានា។ ម្យ៉ាងវិញទៀត វិធានការដែលបានស្នើសុំនេះ ពុំហួសហេតុ ឬ ជាការកែប្រែអ្វីឡើយ ហើយសហព្រះរាជអាជ្ញា បានស្នើសុំឡើងនេះដោយធានាថាលក្ខខណ្ឌដែលបានស្នើឡើងទាំងនេះជាលក្ខខណ្ឌដែលកំហិតសិទ្ធិតិចតួចបំផុត ដែលមានចែងរួចស្រាប់ទៅហើយ។

### គ. វិធានការនៃការដាក់ឲ្យស្ថិតនៅក្រោមការពត្រួតពិនិត្យតាមផ្លូវតុលាការដែលសហព្រះរាជអាជ្ញាបានស្វែងរក មានលក្ខណៈសមស្រប ចាំបាច់ និងសមរម្យ នៅក្នុងកាលៈទេសៈនេះ

16. ដូចបានថ្លែងក្នុងបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាផ្ដល់ជូនសេចក្ដីសន្និដ្ឋាននេះនូវ "ការពិនិត្យលើផ្លូវច្បាប់យ៉ាងលំអិតអំពីលក្ខខណ្ឌ នៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ដើម្បី"បង្ហាញពីភាពសមស្របភាពចាំបាច់ និងភាពសមរម្យ ស្របតាមស្មារតីនៃសិទ្ធិជាមូលដ្ឋាន និងគោលបំណងនៃគោលនយោបាយផ្លូវច្បាប់ដែលបានតម្កល់ក្នុងច្បាប់ជាធរមាន នៅចំពោះមុខ អ.វ.ត.ក"[33]។

---

[32] *Silver និងជនផ្សេងទៀត ទល់នឹង ចក្រភពអង់គ្លេស* (A/61) [1983] 5 តុលាការ EHRR 347, 376 (ដកស្រង់ចេញពី *Handyside ទល់នឹងចក្រភពអង់គ្លេស* (A/24) [1979-80] 1 EHRR 737, 754-755) (តុលាការ ECtHR)។

[33] **E138/1/10/1/1** បណ្ដឹងសាទុក្ខ, កំណត់សំគាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌ១៦។

17. ខណៈដែលទទួលយកថា គេគ្មានទទ្បីករណ៍ណាទៀតដើម្បីបន្តការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជនជាប់ចោទរូបនេះគួរដាក់ឲ្យស្ថិតក្រោមរបបនៃការ**ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដដែល** ហើយការដោះលែងមានលក្ខខណ្ឌចំនួនប្រាំមួយដូចខាងក្រោម គួរត្រូវបាន*បង្គាប់*ដោយអង្គជំនុំជម្រះសាលាដំបូង៖

(១) ឲ្យស្នាក់នៅផ្ទះដែលមានអាស័យដ្ឋានជាក់លាក់ណាមួយ ដែលត្រូវផ្តល់ដោយសហមេធាវីរបស់គាត់។

(២) ឲ្យធ្វើខ្លួនយ៉ាងណាឲ្យអាជ្ញាធរ ឬមន្ត្រីនានាដែលនឹងត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង អាចត្រួតពិនិត្យពីសុវត្ថិភាពចំពោះរូបគាត់ជាប្រចាំសប្តាហ៍។

(៣) ឲ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ។

(៤) មិនឲ្យធ្វើទំនាក់ទំនងទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយសហជនជាប់ចោទផ្សេងទៀតក្នុងសំណុំរឿង០០២ (មិនរាប់បញ្ចូលប្តីរបស់គាត់ អៀង សារី)។

(៥) មិនឲ្យធ្វើទំនាក់ទំនងទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះណាម្នាក់ឡើយដែលបានស្នើស្តាប់សក្ខីកម្មដោយអង្គជំនុំជម្រះសាលាដំបូង និងមិនឲ្យជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាល។

(៦) ឲ្យមានការត្រួតពិនិត្យខាងវេជ្ជសាស្ត្រទៀងរាល់ប្រាំមួយខែម្តង ដែលត្រូវធ្វើឡើងដោយគ្រូពេទ្យដែលត្រូវតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង[34]។

18. ជាដំបូង ដើម្បីបង្ហាញអំពីសមាមាត្ររួមនៃវិធានការនៃការគ្រប់គ្រងតាមផ្លូវតុលាការ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះអាចចង់យោងសំដៅទៅដល់ **ឧបសម្ព័ន្ធចំនួនបី** នៃសេចក្តីសន្និដ្ឋាននេះ។

---

[34] **E138/1/10/1/1** *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ១០។ **E1/119.1** ។ប្រតិចារឹក, ៣១ សីហា ២០១២ ត្រង់ទំព័រទី១០៣។

19. **ឧបសម្ព័ន្ធ ១** ផ្តល់នូវការពិនិត្យតាមកាលប្រវត្តិលើសម្បទាជាគន្លឹះនៅក្នុងករណីនៃការចូលរួមក្នុងសវនាការ ដែលទិន្នន័យអំពីកាលប្រវត្តិសម្អិតនេះអាចរកបាន។ មានករណីចំនួនបួនត្រូវបានទាញយកពីតុលាការ ICTY, មួយករណីទាញពីអង្គជំនុំជម្រះពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ប្រទេសទីម័រខាងកើត) ដែលករណីទាំងអស់នេះត្រូវបានលើកយ៉ាងទូលំទូលាយរួចហើយ នៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ឬជាលាយល័ក្ខណអក្សរ។ មានករណី ECtHR មួយ គឺករណី *Nichitalyov ទល់នឹងប្រទេសអ៊ុយក្រែន,* ដែលមិនបានសួរដេញដោលពីកន្លងមក ហើយទាក់ទងនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាតិប្រឆាំងនឹងជនជាប់ចោទដែលគេបានរកឃើញថា គ្មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការដោយឈរលើទឡ្ហីករណ៍នៃ "ភាពខ្វាក់ទាំងស្រុង និងជាអចិន្ត្រៃយ៍ និងភាពគថ្លង់" ដែល "លទ្ធភាពតាមសម្មតិកម្មនៃការចាប់ផ្តើមឡើងវិញនៃកិច្ចដំណើរការនីតិវិធីនៅតែមាន [ប៉ុន្តែ] ការណ៍នេះគេគ្មានបំណងបន្តនីតិវិធីទាំងនេះនៅពេលបច្ចុប្បន្ននេះទេ"[35]។ នៅក្នុងសាលក្រមសម្រេចសេចក្តីនេះ ទាក់ទននឹងសិទ្ធិទទួលបាន "ការជំនុំជម្រះក្តីក្នុងពេលវេលាមួយសមស្រប" តាមមាត្រា៦(១) នៃអនុសញ្ញា ECHR, ECtHR កំណត់ថា ថិរវេលាណាមួយនៃការបើកកិច្ចដំណើរការនីតិវិធីឡើងវិញក្នុងគោលបំណងនៃ "ការបញ្ជាក់អះអាងលើទឡ្ហីករណ៍សម្រាប់ការផ្អាក ដែលគេហៅថាសម្បទាមិនគ្រប់គ្រាន់របស់អ្នកប្តឹងសុំ" នឹងត្រូវបាន *ទាត់ចោល* ពីការគណនារយៈចម្ងាយនៃកិច្ចដំណើរការនីតិវិធី។ ដ្យាក្រាមភ្ជាប់ជាឧបសម្ព័ន្ធនេះ បង្ហាញពីការកន្លងផុតទៅនៃពេលវេលាក្នុងដំណាក់កាលនិមួយៗនៃដំណើរការនីតិវិធី រួមទាំងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ហើយនិងការបញ្ជាក់អំពីការជម្រះបញ្ចប់ករណីនិមួយៗផង។

20. **ឧបសម្ព័ន្ធ ២** រាយឈ្មោះវិធានការរឹងបន្តឹងដ៏លម្អិតដែលបានបង្គាប់ដោយអង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ទាក់ទងនឹងជនជាប់ចោទដែលទទួលបានការអនុញ្ញាតឲ្យដោះលែង ទោះជាដោយមាន ឬគ្មានលក្ខខណ្ឌក្តី ដោយឈរលើមូលហេតុនៃជម្ងឺធ្ងន់ធ្ងរ រួមទាំងប្រភេទជម្ងឺដែលគេមិននឹកស្មានថានឹងអាចធូរស្រាលឡើងវិញ ជាងជម្ងឺរបស់ អៀង ធីរិទ្ធ ទៅទៀត។ វិសាលភាពនៃលក្ខខណ្ឌដែលបានគេដាក់ទៅលើជនជាប់ចោទដែលមានស្ថានភាពស្រដៀងគ្នា បង្ហាញឲ្យឃើញបន្ថែមទៀតពីសមាមាត្ររួមនៃលក្ខខណ្ឌផ្សេងៗដែលសហព្រះរាជអាជ្ញាបានស្វែងរក។ ជាទិដ្ឋភាពរួមគឺ **ឧបសម្ព័ន្ធ ៣** ផ្តល់សេចក្តីសង្ខេបអំពីលក្ខខណ្ឌផ្សេងៗដែលបានប្រើនៅក្នុងករណីស្រដៀងគ្នាទាំងអស់នេះ។

---

[35] *Nichitaylov ទល់នឹងប្រទេសអ៊ុយក្រែន,* ពាក្យសុំលេខ: 36024/03, ១៥ តុលា ២០០៩ (ECtHR) ត្រង់កថាខណ្ឌ៣៦។

21. ទីពីរ សហព្រះរាជអាជ្ញាលើកអំពីភាពសមស្រប ភាពចាំបាច់ និងសមាមាត្រនៃវិធានការនិមួយៗទាំងនេះ។

## លក្ខខណ្ឌទី១: ជនជាប់ចោទ អៀង ធីរិទ្ធ គួរតម្រូវឱ្យស្នាក់នៅផ្ទះដែលមានអាស័យដ្ឋានជាក់លាក់ណាមួយដែលនឹងត្រូវផ្ដល់ជូនដោយសហមេធាវីរបស់គាត់

22. លក្ខខណ្ឌមួយនេះមានគោលដៅមួយចំនួន រួមទាំងការការពារសុវត្ថិភាពរបស់ជនជាប់ចោទ ការថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ[36] និងការធានាចំពោះវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ បើសិនជាកិច្ចដំណើរការនីតិវិធីត្រូវចាប់ផ្ដើមឡើងវិញនៅពេលអនាគត បើទោះជាការណ៍នេះនៅតែជាលទ្ធភាពនៅឆ្ងាយដាច់ស្រយាលដូចអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ក្ដី[37]។ ដោយសារភាពអសោចរបស់ជនជាប់ចោទ និងប្រវត្តិហានិយភ័យនៃសុវត្ថិភាពរបស់សហជនជាប់ចោទក្នុងសំណុំរឿង00២[38] លក្ខខណ្ឌតម្រូវឱ្យជនជាប់ចោទផ្ដល់អាសយដ្ឋានបច្ចុប្បន្នរបស់គាត់ មកឱ្យតុលាការ គឺជាវិធានការណ្ឋានពានអប្បបរមាតែប៉ុណ្ណោះដែលអង្គជំនុំជម្រះសាលាដំបូង អាចចាប់យកមកអនុវត្តដើម្បីពិនិត្យតាមដានពីសុវត្ថិភាពរបស់គាត់នៅពេលគាត់ត្រូវបានដោះលែង។ លើសពីនេះ លក្ខខណ្ឌនេះធានាថា អង្គជំនុំជម្រះសាលាដំបូង នៅតែដឹងអំពីទីកន្លែងរបស់ជនជាប់ចោទដែលអាចបង្កលទ្ធភាពឱ្យមានការជូនដំណឹងទៅរូបគាត់ អំពីការផ្លាស់ប្ដូរណាមួយនៃការព្យាបាលដែលគេអាចរកបានសម្រាប់ជម្ងឺវិកលចរិតរបស់គាត់ និងការចាប់ផ្ដើមឡើងវិញជាយថាហេតុនៃកិច្ចដំណើរការនីតិវិធី។ ការណ៍នេះមិនត្រឹមតែធានាបានវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការក្នុងករណីមានតម្រូវការប៉ុណ្ណោះទេ គឺថែមទាំងផ្ដល់ជូនជនជាប់ចោទនិងអ្នកអាណាព្យាបាល

---

[36] ដើម្បីប្រៀបធៀប **C20/I/27** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ, ៩ កក្កដា ២00៨, កថាខណ្ឌ៦៤-៧២, ដែលអង្គបុរេជំនុំជម្រះបានរកឃើញថា “ការគំរាមកំហែងតាមការយល់ឃើញ លើបញ្ហាសន្តិសុខ គឺពុំមានជាការបំភ័ន្តន្លែកទេ” (កថាខណ្ឌ៧0) និង **C20/4** ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន, ១0 វិច្ឆិកា ២00៨ ត្រង់កថាខណ្ឌ៣៣ ដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញថា “វាមិនហួសហេតុទេដែលធ្វើការពិចារណាថា សេចក្ដីសម្រេចដោះលែងឱ្យមានសេរីភាពមួយ ក្នុងបរិបទសង្គមកម្ពុជាបច្ចុប្បន្នដែលនៅផុយស្រួយនៅឡើយ នឹងបង្កជាហានិយភ័យ ដែលនាំឱ្យមានការសម្ដែងការមិនពេញចិត្ត និងអាចឈានដល់អំពើហិង្សា”។

[37] **E138/1/10/1/1** បណ្ដឹងសាទុក្ខ, កំណត់សំគាល់*ខាងដើម*លេខ២ ត្រង់កថាខណ្ឌ៦(ខ)។

[38] សូមមើល *ជាឧទាហរណ៍* **C26** ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន (ខៀវ សំផន), ១៧ ធ្នូ ២00៧ ត្រង់កថាខណ្ឌ៣ “... ការសងសឹកដែលនាំឱ្យសន្តិសុខផ្ទាល់ខ្លួនរបស់ជននេះស្ថិតក្នុងសភាពគ្រោះថ្នាក់ ដូចអំពើហិង្សាដែលធ្លាប់កើតមានកាលពីឆ្នាំ១៩៩១ នាពេលដែលជននេះចូលភ្នំពេញវិញ”។

របស់គាត់នូវភាពប្រាកដប្រជាក្នុងកម្រិតមួយយ៉ាងខ្ពស់ ទាក់ទងនឹងឋានៈបន្តជាជនជាប់ចោទរបស់គាត់នៅចំពោះមុខ អ.វ.ត.ក។ លក្ខខណ្ឌនេះមិនបានដាក់បន្ទុកធ្ងន់ធ្ងរទៅលើជនជាប់ចោទទេ ហើយក៏មិនបានដាក់កំហិតលើសេរីភាពនៃការធ្វើដំណើរ ឬសិទ្ធិភាពសេរីភាពរបស់គាត់ដែរ ដោយគ្រាន់តែ តម្រូវឲ្យគាត់រក្សាការជូនដំណឹងតាមរយៈអ្នកអាណាព្យាបាលរបស់គាត់ មកអង្គជំនុំជម្រះសាលាដំបូងអំពីទីកន្លែងនៃលំនៅដ្ឋានបច្ចុប្បន្នរបស់គាត់តែប៉ុណ្ណោះ។

23. អ្នកអាណាព្យាបាលរបស់គាត់មិនត្រូវបានរារាំងពីការផ្លាស់ទីលំនៅរបស់ខ្លួនទេ ដែលស្របទៅនិងករណីយកិច្ចរបស់អ្នកអាណាព្យាបាលនៅក្នុងការ "ប្រឹងប្រែងផ្តល់ការថែទាំព្យាបាលល្អបំផុតតាមដែលអាចធ្វើបាន"[39] សម្រាប់ជនជាប់ចោទ រួមទាំងករណីយកិច្ចទូទៅនៃការថែទាំរបស់អ្នកអាណាព្យាបាល[40]។ អាស្រ័យហេតុនេះ មានការសន្និដ្ឋានថា លក្ខខណ្ឌនេះគឺសមស្របដើម្បីសម្រេចឲ្យបានគោលដៅតាមការអះអាងរបស់ខ្លួន ព្រោះវាជាវិធានការដាក់កំហិតតិចតួចបំផុតដើម្បីសម្រេចគោលដៅទាំងនោះ និងថា ផលប៉ះពាល់របស់វាទៅលើសិទ្ធិ និងសេរីភាពរបស់ជនជាប់ចោទគឺសមាមាត្រទៅនឹងសារៈសំខាន់នៃការធ្វើឲ្យសម្រេចបានគោលដៅនានានៃសុវត្ថិភាព របៀបរៀបរយសាធារណៈ និងភាពប្រាកដប្រជាផ្លូវច្បាប់។

<u>លក្ខខណ្ឌទី២: ជនជាប់ចោទ អៀង ធីរិទ្ធ គួរតម្រូវឲ្យមានវត្តមាននៅពេលមានការត្រួតពិនិត្យជារៀងរាល់សប្តាហ៍ដោយអាជ្ញាធរ ឬមន្ត្រីដែលបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង</u>

24. លក្ខខណ្ឌទីពីរ ក៏មានគោលបំណងថែរក្សារបៀបរៀបរយសាធារណៈ និងការការពារសុវត្ថិភាពបុគ្គលរបស់ជនជាប់ចោទដែរ ដោយហេតុថាវានឹងបង្កលទ្ធភាពឲ្យអាជ្ញាធរអាចតាមដានសុវត្ថិភាព និងសុខមាលភាពរបស់គាត់បានយ៉ាងទៀងទាត់។ ដោយហេតុថាវាគ្រាន់តែតម្រូវជនជាប់ចោទមានវត្តមាននៅពេលមានការចុះមកសួរសុខទុក្ខរបស់អាជ្ញាធរម្តងក្នុងមួយសប្តាហ៍ គេគ្មានបន្ទុកអ្វីផ្សេងដាក់លើជនជាប់ចោទឲ្យធ្ងន់ជាងនេះក្រៅអំពីផលប្រយោជន៍នៃការការពារឡើយ។ សហព្រះរាជអាជ្ញាសូមរំលឹកថា ទាក់ទងនឹងការឃុំឃាំងជនជាប់ចោទជាបណ្តោះអាសន្ននៅក្នុងឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតធ្លាប់បានរកឃើញថា "សេចក្តីសម្រេចមួយដើម្បីដោះលែងជនជាប់ចោទ

[39] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១១១៩(២)។

[40] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១១២៩(១)។

ឲ្យមានសេរីភាពនៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន អាចនឹងបង្កឲ្យមានការសម្តែងការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហិង្សា និងប្រហែលជាអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ជនត្រូវចោទ..."[41]។ លើសពីនេះ លក្ខខណ្ឌនេះមិនបានកម្រិតសិទ្ធិរបស់ជនជាប់ចោទជាដុំកំភួនទេ ជាពិសេសនៅពេលការកំហិតជាសក្តានុពលបណ្តាលមកពីលក្ខខណ្ឌនេះ ត្រូវបានធ្វើតុល្យការធៀបនឹងគោលដៅគោលនយោបាយ ដែលជាការចាំបាច់ក្នុងការដាក់លក្ខខណ្ឌនេះ។

## លក្ខខណ្ឌទី៣: ជនជាប់ចោទ អៀង ធីរិទ្ធ គួរតែតម្រូវឲ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់គាត់

25. លក្ខខណ្ឌនៃការដកហូតលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់គាត់ ផ្តល់នូវការធានាចំពោះជនរងគ្រោះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងការិយាល័យសហព្រះរាជអាជ្ញាថា អៀង ធីរិទ្ធ នឹងមិនចាកចេញពីកម្ពុជាឡើយ បើសិនជាការចាប់ផ្តើមឡើងវិញនៃកិច្ចដំណើរការនីតិវិធីអាចធ្វើបាននៅពេលអនាគត។ លក្ខខណ្ឌនេះអនុញ្ញាតឲ្យមានការធានាឡើងវិញបន្ថែមទៀត ចំពោះសាធារណជនកម្ពុជា និងសហគមន៍អន្តរជាតិថា ជនជាប់ចោទនឹងមិនអាចគេចវេះពីយុត្តិធម៌បានឡើយ និងថែមទាំងបង្ហាញឲ្យឃើញបន្ថែមទៀត ដូចអង្គជំនុំជម្រះសាលាដំបូងបានសង្កត់ធ្ងន់ក្នុងសេចក្តីសម្រេចដែលរងការជំទាស់នេះថា "បទចោទទាំងឡាយប្រឆាំងនឹងជនជាប់ចោទមិនត្រូវបានដកចេញឡើយ ហើយសេចក្តីសម្រេច[ដោះលែងគាត់]នេះ មិនមែនសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ឡើយ ទាក់ទងនឹងបទចោទនានាប្រឆាំងនឹងរូបគាត់នៅក្នុងសំណុំរឿង០០២"[42] ដោយហេតុតែភាពចាំបាច់ណាមួយក្នុងការការពារលទ្ធភាពនៅពេលអនាគតអំពីការបន្តសវនាការឡើងវិញ។

26. លក្ខខណ្ឌនៃការដកហូតលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់គាត់ មិនកំហិតព្រំដែនសេរីភាពនៃការធ្វើដំណើររបស់ជនជាប់ចោទក្នុងវិសាលភាពធំធេងណាមួយឡើយ ប៉ុន្តែការធ្វើដូច្នេះដោយប្រើមធ្យោបាយដាក់កំហិតតិចតួចបំផុត។ អង្គជំនុំជម្រះសាលាដំបូងបន្តរក្សាឆន្ទានុសិទ្ធិក្នុងការផ្តល់ឯកសារទាំងនេះត្រឡប់ទៅឲ្យអ្នកអាណាព្យាបាលរបស់ជនជាប់ចោទវិញ សម្រាប់គោលបំណងជាក់លាក់ ដូចជា ការធ្វើដំណើរទៅបរទេសដើម្បីព្យាបាលសុខភាពដែលអាចតម្រូវឲ្យធ្វើដូច្នេះ។

---

[41] **C20** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (អៀង ធីរិទ្ធ), ១៤ វិច្ឆិកា ២០០៧ ត្រង់កថាខណ្ឌ៦។

[42] **E138/1/10** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សំគាល់*ខាងដើម* លេខ៥ ត្រង់ថាខណ្ឌ៤០។

ទាក់ទងនឹងចំណុចនេះ សហព្រះរាជអាជ្ញាសូមរំលឹកឡើងវិញថា ទាំងនៅក្នុងកិច្ចព្រមព្រៀង ទាំងក្នុងច្បាប់អ.វ.ត.ក និងទាំងនៅក្នុងវិធានផ្ទៃក្នុង គេគ្មានមូលដ្ឋានដើម្បី *បង្ខំ* ឲ្យមានវត្តមានរបស់ជនជាប់ចោទ ពេលជននោះនៅក្រៅដែនយុត្តាធិការរបស់កម្ពុជាឡើយ ទោះបីជាគេមានធម្មោបាយតាមលិខិតអញ្ជើញដែលគ្មានភាពប្រាកដប្រជាទៅកាន់ប្រទេសទីបីណាមួយ ដើម្បីជាជំនួយក្តី[43]។

<u>លក្ខខណ្ឌទី ៤ និង ៥៖ ជនជាប់ចោទ អៀង ធីរិទ្ធ គួរត្រូវហាមឃាត់ កុំឲ្យទាក់ទង ដោយត្រង់ៗក្តី ឬ ដោយប្រយោលក្តី ជាមួយនឹងសហជនជាប់ចោទដទៃទៀត (លើកលែងតែស្វាមីរបស់គាត់ គឺជនជាប់ចោទ អៀង សារី), ជាមួយនឹងសាក្សី អ្នកជំនាញ ឬ ជនរងគ្រោះរូបណាក៏ដោយដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំស្តាប់ចម្លើយ និងមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការទេ</u>

27. លក្ខខណ្ឌទាំងនេះគឺចាំបាច់ដើម្បីការពារសុចរិតភាព និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដែលកំពុងបន្តធ្វើនៅក្នុងសំណុំរឿង ០០២។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលស្គាល់រួចហើយថាកាតព្វកិច្ចបែបដូច្នេះគឺជនជាប់ចោទត្រូវបំពេញ ទៅតាមវិធាន៣៥ ហើយធ្លាប់បានធ្វើការបញ្ជាក់សាជាថ្មីឡើងវិញអំពីសារៈសំខាន់នេះ[44]។ ដោយសារតែគេមិនបានកម្រិតជនជាប់ចោទអំពីការធ្វើការទាក់ទងជាមួយនឹងស្វាមីរបស់គាត់ គឺជនជាប់ចោទ អៀង សារី នោះហើយ ទើបសិទ្ធិឯកជន ឬ សិទ្ធិរស់នៅជាគ្រួសាររបស់គាត់ មិនត្រូវបានរាំងខ្ទប់តាមមធ្យោបាយណាមួយ ដោយការដាក់លក្ខខណ្ឌបែបដូច្នេះនោះឡើយ។

28. លើសពីនេះទៅទៀត លក្ខខណ្ឌនេះមានមូលដ្ឋានច្បាស់លាស់មួយនៅក្នុងវិធាន៣៥ ក៏ដូចជានៅក្នុងច្បាប់កម្ពុជាដែរ[45]។ ដូច្នេះ លក្ខខណ្ឌនេះមិនមានដាក់បន្ទុកណាមួយទៅលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយវិធានផ្ទៃក្នុងសម្រាប់ អវតក ឲ្យបានធ្ងន់ធ្ងរជាងបន្ទុកដែលបានដាក់រួចហើយទៅលើប្រជាពលរដ្ឋកម្ពុជាដទៃទៀតនោះឡើយ។

---

[43] វិធាន៥(១) នៃវិធានផ្ទៃក្នុង។

[44] **E138/1/10** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងលើ*លេខ៥ ត្រង់កថាខណ្ឌទី៣៨។

[45] សូមអានជាទូទៅ, ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, គន្ថីទី៤, មាតិកាទី២។

**លក្ខខណ្ឌទី ៦៖ ជនជាប់ចោទ អៀង ធីរិទ្ធ គួរតម្រូវឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ រៀងរាល់ប្រាំមួយខែម្ដង ដោយអ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រ ដែលអង្គជំនុំជម្រះសាលាដំបូង បានចាត់តាំង**

29. លក្ខខណ្ឌចុងក្រោយដែលសហព្រះរាជអាជ្ញាបានស្នើឡើងនេះ ជាចាំបាច់លេចចេញមកពីលក្ខណៈមិនជាក់លាក់ ជាជាងលក្ខណៈអចិន្ត្រៃយ៍ នៃការផ្អាកកិច្ចដំណើរការនីតិវិធីដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់។ ដោយសារតែ៖ ទី១) ការទទួលយករបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការប្រែប្រួលនៅក្នុងកាលៈទេសៈនៃសុខភាពផ្លូវចិត្ត និងសមត្ថភាពខាងសតិបញ្ញារបស់ជនជាប់ចោទ ប៉ះពាល់ទៅលើសម្បទាក្នុងការចូលរួមសវនាការ ដូច្នេះ វានឹងនាំទៅដល់យ៉ាងមានសក្ដានុពលនូវការបន្តធ្វើកិច្ចដំណើរការវិធីទៅទៀត, និង ទី២) ចេតនារបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយនឹងអ្នកជំនាញវេជ្ជសាស្ត្រអំពីការចម្រើនជឿនលឿនណាមួយនៃថ្នាំពេទ្យ ឬការព្យាបាលជំងឺវង្វេងស្មារតី (dementia)[46] នោះហើយទើបវាជាការមួយច្បាស់លាស់ណាស់ ដែលថាការវាយតម្លៃរហូតមកដល់ពេលបច្ចុប្បន្ននេះ ទៅលើសុខភាព និងសម្បទារបស់ជនជាប់ចោទ ត្រូវតែជាលក្ខខណ្ឌដែលមានជាប់ជាមួយនឹងការផ្អាកកិច្ចដំណើរការនីតិវិធីមួយដែលមិនជាក់លាក់។ ការវាយតម្លៃបែបដូច្នេះ គឺជាការចាំបាច់មួយនាពេលក្រោយមកទៀតសម្រាប់ពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយនឹងអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីឲ្យបានជាអត្ថន័យណាមួយក៏ដោយ ដោយសារអ្នកជំនាញមុខជាចាំបាច់ត្រូវដឹងពីស្ថានភាពបច្ចុប្បន្ននៃសុខភាពរបស់ជនជាប់ចោទ ដើម្បីឲ្យខ្លួនមានលទ្ធភាពផ្ដល់កិច្ចប្រឹក្សាទាក់ទងនឹងការចម្រើនជឿនលឿនផ្នែកវេជ្ជសាស្ត្រណាមួយ ជូនដល់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះហើយ ការពិនិត្យផ្នែកវេជ្ជសាស្ត្រទៅលើជនជាប់ចោទ រៀងរាល់ពាក់កណ្ដាលឆ្នាំម្ដង គឺជាវិធីសាស្ត្រមួយសមស្រប និងសមហេតុផល សម្រាប់ធានាថា វាត្រូវទៅតាមលក្ខខណ្ឌនានានៃការផ្អាកកិច្ចដំណើរការនីតិវិធី ហើយបើដូច្នេះនោះ គេនឹងបន្តអនុញ្ញាតឲ្យមានការផ្អាកនេះបាន។ ដូចដែលបានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ១** តុលាការព្រហ្មទណ្ឌអន្តរជាតិជាទូទៅតម្រូវឲ្យមានការពិនិត្យផ្នែកវេជ្ជសាស្ត្រជាទៀតទាត់ បន្ទាប់ពីមានការដោះលែងជាបណ្ដោះអាសន្ន។ ទោះជាយ៉ាងណាក្ដី ខ្លឹមសារនៅពេលនេះ អាចឈានដល់បានល្អ នៅពេលអង្គជំនុំជម្រះអាចរកឃើញថា ការពិនិត្យឡើងវិញបែបនេះគួរបញ្ចប់។

---

[46] **E138/1/10** សេចក្ដីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ៥ ត្រង់កថាខណ្ឌទី៣៩។

30. បន្ថែមលើនេះ លក្ខខណ្ឌដែលបានស្នើឡើងនេះ គឺមានកម្រិតនៅត្រឹមការពិនិត្យស្ថានភាពខាងផ្លូវចិត្ត ដោយអ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រ ហើយមិនអះអាងថាត្រូវបង្ខំជនជាប់ចោទឲ្យស្ថិតនៅក្រោមការព្យាបាលណាបែបណាមួយដោយពុំមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅរបស់គាត់ឡើយ។ ការពិនិត្យផ្នែកវេជ្ជសាស្ត្រ (និងតាមពិតការព្យាបាល) គឺជាវិធានការនៃសមត្ថកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ នៅក្រោមច្បាប់កម្ពុជា[47]។ ដូចជាអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានអនុវត្តនៅក្នុងករណីរបស់ *Talić* ថា៖

> *ដោយយោងទៅតាមករណីយុត្តិសាស្ត្ររបស់តុលាការ ICTY វាគឺជាការខូចខាតយ៉ាងធ្ងន់ធ្ងរដល់អាជ្ញាធរស្ថាប័នតុលាការ បើអង្គជំនុំជម្រះមិនយកចិត្តទុកដាក់លើការពិតទាំងស្រុងនៃលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ជនជាប់ចោទ ហើយមិនអើពើនឹងអង្គហេតុដែលថាវាគឺជាតុលាការដែលបានបង្កើតមកដើម្បី អះអាង ការពារ និង អនុវត្តច្បាប់សិទ្ធិមនុស្ស*[48]*។*

ហេតុដូច្នេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានដោយគោរពថា លក្ខខណ្ឌចុងក្រោយ សម្រាប់ការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធិ គឺត្រូវតាមពិសោធន៍សមាមាត្រ ដោយហេតុថាវាមានលក្ខណៈសមស្រប ចាំបាច់ និងផលប៉ះពាល់របស់វាគឺសមាមាត្រទៅនឹងភាពសំខាន់នៃគោលបំណងធ្វើការត្រួតពិនិត្យលក្ខខណ្ឌនានានៃការផ្អាកកិច្ចដំណើរការនីតិវិធី ដែលមិនជាក់លាក់មួយ។

## III. **សំណើ**

31. ចំពោះមូលហេតុបន្ថែមទាំងនេះដូចដែលបានស្នើនៅក្នុងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះត្រូវ៖

(ក) សម្រេចថាបណ្តឹងសាទុក្ខមួយនេះ គឺអាចទទួលយកបានទាំងស្រុង,

---

[47] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ២២៣(១១)។

[48] *រដ្ឋអាជ្ញា ទល់នឹង* Momir Talić, កំណត់សម្គាល់*ខាងលើ* លេខ២០ ត្រង់ទំព័រទី៦។

(ខ) ទុកជាមោឃៈនូវសេចក្ដីសម្រេចដែលរងការជំទាស់នេះ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខ្លួនពុំមានយុត្តាធិការដើម្បីចេញបង្គាប់ឲ្យមានការបន្តការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយអាស្រ័យលើលក្ខខណ្ឌគតិយុត្តិឡើយ, និង

(គ) ធ្វើការកែប្រែសេចក្ដីសម្រេចដែលរងការជំទាស់នេះ ដើម្បីតម្រូវជនជាប់ចោទ តាមរយៈអ្នកអាណាព្យាបាលទូទៅ ឲ្យអនុវត្តតាមលក្ខខណ្ឌជាក់លាក់នានាដែលសហព្រះរាជអាជ្ញាបានស្នើឡើង ក្នុងគោលបំណងដើម្បីធ្វើការការពារឲ្យបានត្រឹមត្រូវនូវសិទ្ធិដែលកំពុងជំទាស់គ្នានេះ ជាមួយនឹងផលប្រយោជន៍តាមផ្លូវច្បាប់ដែលបានចូលមកពាក់ព័ន្ធតាមរយៈការដោះលែងពីមន្ទីរឃុំឃាំង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** WilliamSMITH<br>សហព្រះរាជអាជ្ញារង | | |